**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ ៣៤៧ ក.ប/សរ.ន.ក

*រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១៦*

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បេក្ខជនទាំងអស់ឱ្យបានជ្រាបថា **លទ្ធផលជាប់ជាស្ថាពរ និងជាប់បម្រុង នៃការប្រឡងជ្រើសរើសមន្ត្រីរាជការក្របខ័ណ្ឌថ្មីកាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៦ នៅវិទ្យាល័យ ជា ស៊ីម សន្ធរម៉ុក នឹងបិទប្រកាសនៅទីស្តីការក្រសួង និងវិទ្យាល័យ ជា ស៊ីម សន្ធរម៉ុក នាថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ វេលាម៉ោង ២៣:០០ នាទីយប់នេះ។**

ដោយឡែកដើម្បីឱ្យមានតម្លាភាពចំពោះបេក្ខជន ដែលបានប្រឡងជាប់ជាស្ថាពរ នៅទីស្តីការក្រសួង (ថ្នាក់កណ្តាល) ចំនួន **៤៣នាក់** ក្រសួងនឹងធ្វើការរៀបចំ បែងចែកប៉ុស្តិ៍ និងជ្រើសរើសកន្លែងបម្រើការងាររបស់មន្ត្រីនីមួយៗ ដោយទុកឱកាសឱ្យអ្នកដែលមានចំណាត់ថ្នាក់ខ្ពស់ និងថ្នាក់បន្តបន្ទាប់ មានសិទ្ធិជ្រើសរើសប៉ុស្តិ៍ (អង្គភាពដែលខ្លួនចង់ទៅបម្រើការងារ) រៀងៗខ្លួន **នាថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅទីស្តីការក្រសួង វេលាម៉ោង ០៩:០០ នាទីព្រឹក។**

❖ **បញ្ជាក់៖** បេក្ខជនដែលបានប្រឡងជាប់ជាស្ថាពរ និងបានជ្រើសរើសប៉ុស្តិ៍បម្រើការងាររួចទាំងអស់ (ទីស្តីការក្រសួង និងមន្ទីរ ក.ប ថ្នាក់រាជធានី-ខេត្ត) **ត្រូវចូលរួមប្រជុំស្តាប់ការណែនាំ និងបំពេញឯកសារផ្សេងៗជាមួយនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក នាថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅសាលប្រជុំ B នៃទីស្តីការក្រសួង វេលាម៉ោង ០៩:០០ នាទីព្រឹក។**

**ចំពោះបេក្ខជនដែលអវត្តមាន មិនបានចូលរួមតាមការអញ្ជើញនេះ ក្រសួងចាត់ទុកថាឯកភាពតាមការចាត់តាំងរបស់ក្រសួង ដោយមិនអាចតវ៉ា ឬស្នើសុំផ្លាស់ប្តូរនៅពេលក្រោយបានឡើយ។**

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម បេក្ខជន ទាំងអស់ជ្រាបជាព័ត៌មាន។

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ និងជា**

**ប្រធានគណៈកម្មការរៀបចំការប្រឡង**

**ភាន់ ម៉ន**

ព័ត៌មានបន្ថែមសូមទំនាក់ទំនង:

- លោក ប៉ក់ ហឿន ០១១ ៩៤៣ ១៣៧
- លោក ងួន ឆេង ០១២ ៧៣៣ ៤១១
- លោក គួយ គឿន ០៧៧ ៥១៨ ៥១១

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៥